នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ព័ត៌មានពិស្តារនៃការដាក់ឯកសារ

សំណុំរឿងលេខ	:	០០២/១៩-០៩-២០០៧-អវតក/អជសដ
ដាក់ទៅ	:	អង្គជំនុំជម្រះសាលាដំបូង
ថ្ងៃដាក់	:	ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៤
ភាគីអ្នកដាក់	:	សហព្រះរាជអាជ្ញា
ភាសាដើម	:	អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 04-Sep-2014, 11:00
CMS/CFO: Sann Rada

ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំផ្អាកកិច្ចដំណើរការនីតិវិធី ឬប្ដឹងជំទាស់ចៅក្រម

អ្នកដាក់ឯកសារ:

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Marie GUIRAUD

អ្នកទទួលឯកសារ:

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Claudia FENZ
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

ចម្លងជូន:

ជនជាប់ចោទ:
នួន ជា
ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN

I. សេចក្តីផ្តើម

១- នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ មេធាវីការពារក្តី ខៀវ សំផន (“មេធាវីការពារក្តី ខៀវ សំផន”) បានស្នើឲ្យពិចារណាឡើងវិញចំពោះការបដិសេធលើសំណើរបស់ជនជាប់ចោទ សុំផ្អាកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០២ រង់ចាំរហូតដល់មានសាលដីកាស្ថាពរក្នុងសំណុំរឿង០០២/០១[1] សិន។ ក្នុងករណីសុំផ្អាកនេះមិនបានផ្តល់ជូន មេធាវីការពារក្តី ខៀវ សំផន គំរាមថាខ្លួននឹងស្វែងរក “récusation”[2] (មានន័យថា បណ្តឹងជំទាស់) ចំពោះចៅក្រមអង្គជំនុំជម្រះសាលាដំបូងទាំងអស់ (“អង្គជំនុំជម្រះ”) និងសមាសភាពចៅក្រមថ្មីដែលនឹងត្រូវស្តាប់កិច្ចដំណើរការនីតិវិធីបន្ថែមក្នុងសំណុំរឿង០០២ (“សំណើ”)[3]។

២- សហព្រះរាជអាជ្ញាសន្និដ្ឋានថា: (១) ការផ្អាកកិច្ចដំណើរការនីតិវិធីមិនអនុញ្ញាតឡើយនៅក្នុងកាលៈទេសៈនេះ ហើយសំណើសុំដំណោះស្រាយបឋមមិនត្រូវផ្តល់ជូនដែរដោយអង្គជំនុំជម្រះ **(ផ្នែក II(ក)**ខាងក្រោម; (២) សំណើប្តឹងជំទាស់មានលក្ខខណ្ឌអាស្រ័យទៅលើសំណើបឋម មិនបានអនុញ្ញាតទេ ដោយមិនអនុវត្តតាមវិធាន៣៤ **(ផ្នែកII(ខ)**ខាងក្រោម និង (៣) ដោយសារគ្មានមូលដ្ឋានសម្រាប់ប្តឹងជំទាស់ចៅក្រមអង្គជំនុំជម្រះ មិនឲ្យបន្តកិច្ចដំណើរការនីតិវិធីទៅមុខទៀតក្នុងសំណុំរឿង០០២ សំណើសុំដំណោះស្រាយមានលក្ខខណ្ឌទីពីរ គឺគ្មានមូលដ្ឋាន ហើយក៏មិនអនុញ្ញាតឲ្យពន្យារកិច្ចដំណើរការនីតិវិធីដែរ **(ផ្នែកII(គ)** ខាងក្រោម។

II. ច្បាប់ជាធរមាន និងអំណះអំណាង

ក. គ្មានមូលដ្ឋានសម្រាប់ការផ្អាកកិច្ចដំណើរការនីតិវិធីឡើយ

៣- មេធាវីការពារក្តី ខៀវ សំផន ឲ្យដឹងថា ការពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ លេខ **E301/5/1/1** – ដែលអង្គជំនុំជម្រះបានបដិសេធមិនឲ្យផ្អាកកិច្ចដំណើរការនីតិវិធីរង់ចាំ

---

[1] **E301/5/5/1** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារពេលការចាប់ផ្តើមសវនាការលើសំណុំរឿង០០២/០២ រហូតដល់មានសាលក្រមស្ថាពរលើសំណុំរឿង០០២/០១, ២១ មីនា ២០១៤។

[2] **E314/1** សំណើរបស់លោក ខៀវ សំផន សុំឲ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង០០២/០១ ចូលជាស្ថាពរមុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង០០២/០២ និងសុំឲ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមជំនុំជម្រះថ្មីមួយ, ២៥ សីហា ២០១៤ ត្រង់កថាខណ្ឌ៤៨ (“សំណើរបស់មេធាវីការពារក្តី”)។

[3] *ដដែលដូចខាងលើ*, ត្រង់កថាខណ្ឌ៤៦-៤៨។

រហូតដល់ការសម្រេចលើបណ្តឹងសាទុក្ខចុងក្រោយក្នុងសំណុំរឿង០០២/០១ - គឺត្រូវបានអនុញ្ញាត តាមមូលដ្ឋានចំនួនពីរៈ (ក) អង្គជំនុំជម្រះបានធ្វើហួសពីវិសាលភាពសវនាការនៅក្នុងការសម្រេច របស់ខ្លួនក្នុងសំណុំរឿង០០២/០១ និងថា (ខ) អង្គជំនុំជម្រះតុលាការកំពូលបាន "ទុកជាមោឃៈ" នូវការផ្តល់សម្អាងផ្លូវច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការច្រានចោលសំណើសុំផ្អាកកិច្ច ដំណើរការនីតិវិធីពីមុនរបស់មេធាវីការពារក្តី ខៀវ សំផន[4]។

៤- មេធាវីការពារក្តី ខៀវ សំផន ឲ្យដឹងថា សេចក្តីសម្រេចពីមុនរបស់អង្គជំនុំជម្រះ គួរត្រូវយកមក ពិចារណាឡើងវិញដោយហេតុថា ហានិភ័យនៃការប៉ះពាល់បែបអគ្គនោម័តដែលមេធាវីបានស្វែង រកដើម្បីបញ្ចៀសក្នុងសំណើបឋមរបស់ខ្លួនពិតជាមានប្រាកដមែន នេះបើតាមការយល់ឃើញរបស់ ភាគីនោះ[5]។ មេធាវីតវ៉ាថា អង្គជំនុំជម្រះបានសម្រេចជាមុនលើអង្គហេតុទាំងឡាយដែលមិនទាន់ បានប្តឹងមកខ្លួន ដូច្នេះនេះគឺការរំលោភលើសច្ចធារណ៍នៃនិរទោស និងសិទ្ធិរបស់ ខៀវ សំផន ក្នុង ការទទួលបានការជំនុំជម្រះដោយតុលាការមិនលម្អៀង[6]។ តាំងពីដើមមក អំណះអំណាងសម្រាប់ សុំឲ្យពិចារណាឡើងវិញនេះ គឺជារឿងច្រំដែលម្តងហើយម្តងទៀត ហើយប្រសិនបើទទួលយកមែន នោះ អាចធ្វើឲ្យសុពលភាពនៃសេចក្តីសម្រេចរបស់តុលាការ ទទួលនូវការពិចារណាឡើងវិញ ដោយមិនចេះចប់ ដោយគ្រាន់តែពឹងផ្អែកទៅលើគំនិតអគ្គនោម័តរបស់គូភាគីចំពោះកិច្ចដំណើរការ នីតិវិធីតែប៉ុណ្ណោះ។

៥- សំណើរបស់ ខៀវ សំផន ពឹងផ្អែកលើការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលដែលសម្រេច ថា៖ (ក) សំណុំរឿង០០២/០១ និងសំណុំរឿង០០២/០២ គឺជា "ជាការជំនុំជម្រះដាច់ដោយឡែក ពីគ្នា និងខុសគ្នា" មិនមែនជាផ្នែកមួយនៃកិច្ចដំណើរការនីតិវិធីសវនាការដែលកំពុងបន្តនេះទេ[7] និង (ខ) មានហានិភ័យចំពោះ "ការប៉ះពាល់ជាក់ស្តែង" មួយចំពោះជនជាប់ចោទ ប្រសិនបើការរក ឃើញក្នុងសំណុំរឿង០០២/០១ "បណ្តាលឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ" ចំពោះជនជាប់ ចោទ គឺអាចជាន់គ្នាជាមួយនឹងការរកឃើញនៅក្នុងសំណុំរឿង០០២/០២[8] ជាមួយនឹងការបដិសេធ

---

[4] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌ៦-៧។

[5] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌ១០។

[6] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌ៤២។

[7] **E301/9/1/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ និងវិសាលភាពនៃសំណុំរឿង០០២/០២, ២៩ កក្កដា ២០១៤ ត្រង់កថាខណ្ឌ៧០ ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន")។

[8] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌ៨៥។

យ៉ាងខ្លាំងអំពីសច្ចធារណ៍នៃអនាគតិ ដែលមានជាប់មកជាមួយនឹងចៅក្រមអាជីពដែលត្រូវស្តាប់សវនាការនៅក្នុងសំណុំរឿង០០២/០២[9]។

៦- ការសម្រេចទាំងនេះ ពុំមានផលប៉ះពាល់ជាក់ស្តែងទៅលើសេចក្តីសម្រេចមុនៗរបស់អង្គជំនុំជម្រះទេ ដែលបដិសេធសំណើសុំផ្អាកកិច្ចដំណើការនីតិវិធីក្នុងសំណុំរឿង០០២/០២ រង់ចាំបណ្តឹងសាទុក្ខចុងក្រោយក្នុងសំណុំរឿង០០២/០១។ ដូច្នេះ សំណើសុំផ្អាកគួរបានបដិសេធចោល។ គោលជំហរនេះត្រូវបានគាំទ្រដោយមូលដ្ឋានពាក់ព័ន្ធចំនួនពីរ។ ទីមួយ បញ្ហាថាតើអង្គជំនុំជម្រះអាចចាប់ផ្តើមសំណុំរឿង០០២/០២ មុនបណ្តឹងសាទុក្ខចុងក្រោយក្នុងសំណុំរឿង០០២/០១ ដែរឬទេ គឺត្រូវបានដោះស្រាយចប់សព្វគ្រប់ហើយដោយអង្គជំនុំជម្រះតុលាការកំពូល និងមិនអាចឲ្យមេធាវីការពារក្តី ខៀវ សំផន លើកយកមកតវ៉ាជាថ្មីចំពោះមុខអង្គជំនុំជម្រះនេះទៀតឡើយ។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីថ្មីបំផុត បង្ហាញយ៉ាងច្បាស់ពីការចាប់ផ្តើមសវនាការក្នុងសំណុំរឿង០០២/០២ នៅមុនពេលការប្រកាសសាលដីកាស្ថាពរលើបណ្តឹងសាទុក្ខសំណុំរឿង០០២/០១[10]។ ទីពីរ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឲ្យចាប់ផ្តើមដំណើរការនីតិវិធីសំណុំរឿង០០២/០២ "ឲ្យបានឆាប់តាមដែលអាចធ្វើបាន" ដែលការបង្គាប់មិនស៊ីសង្វាក់គ្នាទៅនឹងសំណើសុំផ្អាកកិច្ចដំណើរការនីតិវិធីដែលបានពន្យារពេលឡើយ[11]។

៧- ការអះអាងដែលថា សាលក្រមសំណុំរឿង០០២/០១ អាចនាំឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌដល់ ខៀវ សំផន លើអង្គហេតុទាំងឡាយស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ ប៉ុន្តែស្ថិតក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ គឺមិនត្រឹមត្រូវតាមអង្គហេតុទេ។ ចំណុចនេះត្រូវបានលើកមកពិភាក្សាបន្ថែមខាងក្រោម ដើម្បីដោះស្រាយសំណើមានលក្ខខណ្ឌរបស់មេធាវីក្នុងការប្តឹងជំទាស់ដិតចិត្ត។

---

[9] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌ៨៣។

[10] **E284/4/7** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២: សេចក្តីសង្ខេបនៃសំអាងហេតុ, ២៣ កក្កដា ២០១៣ ត្រង់កថាខណ្ឌ៣៥ ["ការរំពឹងទុកសម្រាប់សំណុំរឿង០០២/០២ ថានឹងត្រូវបញ្ជូនទៅជំនុំជម្រះ និងការឈានដល់ការចេញសាលក្រម ឥឡូវនេះកាន់តែខិតចូលមកដល់ហើយជាងពេលមុនៗទៅទៀត"]; កថាខណ្ឌ៧១ ["សំណុំរឿង០០២/០២ ត្រូវចាប់ផ្តើមយ៉ាងឆាប់បំផុតតាមដែលអាចធ្វើបាន បន្ទាប់ពីបញ្ចប់សេចក្តីសន្និដ្ឋានបិទក្នុងសំណុំរឿង០០២/០១"]។

[11] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌ៧២។ ["សំណុំរឿង០០២/០២ ត្រូវចាប់ផ្តើមឆាប់បំផុតតាមដែលអាចធ្វើបាន នៅក្រោយការបញ្ចប់សេចក្តីសន្និដ្ឋានបិទក្នុងសំណុំរឿង០០២/០១"]។ **E301/9/1/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន, កំណត់សម្គាល់ *ខាងដើម* លេខ៧ ត្រង់កថាខណ្ឌ៦។

ខ. សំណើមានលក្ខខណ្ឌសម្រាប់ការប្តឹងជំទាស់ដំណើរការនីតិវិធីនេះ មិនបានអនុវត្តតាមវិធានផ្ទៃក្នុងទេ

៨- វិធាន៣៤(២)នៃវិធានផ្ទៃក្នុង ចែងថា ភាគីអាចធ្វើបណ្តឹងជំទាស់ចំពោះចៅក្រមណាម្នាក់ "ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬធ្លាប់មានការជាប់ពាក់ព័ន្ធណាមួយ ដែលអាចធ្វើឲ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬអាចបង្កើតឲ្យមានភាពលម្អៀង[12]។ អនុលោមតាមវិធាន៣៤(៣) បណ្តឹងដូច្នេះ "ត្រូវបង្ហាញឲ្យច្បាស់លាស់អំពីមូលហេតុនៃបណ្តឹង និងត្រូវមានភស្តុតាងបញ្ជាក់ផងដែរ[13]។ អង្គជំនុំជម្រះនេះបានបញ្ជាក់រួចហើយថា វិធាន៣៤ "ផ្តល់អាណត្តិអំពីការដាក់បណ្តឹងជំទាស់ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីស្នើសុំបានដឹងអំពីមូលហេតុនោះ"[14]។

៩- ពុំមានចំណុចណាមួយមានចែងក្នុងច្បាប់ជាធរមានដែលថា ការប្តឹងជំទាស់គឺជាឧបាស្រ័យ *ជាជម្រើសសមស្របមួយឡើយ* ដូចដែលបានប្តឹងនៅក្នុងសំណើរបស់ ខៀវ សំផន ជាពិសេសក្នុងទម្រង់នៃការគំរាមប្តឹងជំទាស់ ប្រសិនបើអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យផ្អាកកិច្ចដំណើរការនីតិវិធីដែលគ្រោងថា នឹងមានរយៈពេលរហូតដល់ជាងមួយឆ្នាំ រហូតដល់ការប្រកាសសាលដីកាក្នុងសំណុំរឿង ០០២/០១នោះទេ។ តាមគម្រោងនៃវិធាន៣៤(២) ដូចបានលើកយោងខាងលើ មានការរំពឹងទុកថា បើសិនមូលដ្ឋានសម្រាប់ការប្តឹងជំទាស់ចំពោះចៅក្រមអង្គជំនុំជម្រះមានមែន នោះភាគីដែលស្នើសុំដោយដឹងបែបអត្តនោម័តអំពីមូលហេតុនៃការប្តឹងជំទាស់ត្រូវលើកបញ្ហានេះជាបន្ទាន់ជាមួយអង្គជំនុំជម្រះ។ ប៉ុន្តែមូលដ្ឋានសម្រាប់ប្តឹងជំទាស់ ទោះបីជាមិនត្រឹមត្រូវដោយ មិនត្រូវបានលើកឡើងទាំងអស់ដោយភាគីដាក់ពាក្យសុំ និងមិនត្រូវបាន "កំណត់ឲ្យបានឆាប់រហ័ស"[15] នោះទេ មានន័យថា បានបញ្ជាក់ជារួម ឬបានច្រានចោលលើភាពមន្ទិលសង្ស័យដែលមានចំពោះសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីអន្តរាគមន៍ ដែលជាឧបសគ្គដល់ការគ្រប់គ្រងយុត្តិធម៌ត្រឹមត្រូវ។ ប្រសិនបើមេធាវីការពារក្តី ខៀវ សំផន ជឿជាក់ពិតប្រាកដមែនថា ខ្លួនមានមូលដ្ឋានត្រឹមត្រូវសម្រាប់

[12] វិធាន៣៤(២) នៃវិធានផ្ទៃក្នុង។

[13] វិធាន៣៤(៣) នៃវិធានផ្ទៃក្នុង។

[14] **E5/3** សេចក្តីសម្រេចលើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ, ២៨ មករា ២០១១ ត្រង់កថាខណ្ឌ១២ [សង្កត់ន័យត្រង់ឃ្លាដែលមានគូសបន្ទាត់ពីក្រោម]។

[15] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌ២។

សំណើសុំនេះ នោះគេត្រូវធ្វើសារណាសន្និដ្ឋានក្នុងពេលនេះ ស្របតាមវិធាន៣៤(២) មិនមែនគំរាមថា ពួកគេនឹងធ្វើដូចនេះ ប្រសិនបើសំណើសុំផ្អាកសវនាការដែលមានរយៈពេលមួយឆ្នាំ មិនត្រូវបានអនុញ្ញាតនោះ។ សហព្រះរាជអាជ្ញាបានយល់តាមពាក្យពេចន៍ដែលបញ្ជូនពីលោកប្រធានអង្គជំនុំជម្រះ ជូនទៅលោកប្រធានគណៈកម្មាធិការរដ្ឋបាលតុលាការ[16] ដែលថា អង្គជំនុំជម្រះបានសម្រេចថា នឹងចាត់ទុកញត្តិស្នើសុំនេះដូចជាបណ្តឹងសុំប្តឹងដឹតចិត្តចៅក្រមបច្ចុប្បន្នទាំងអស់ និងជម្រុញឲ្យអង្គចៅក្រមពិសេស ផ្តួចផ្តើមនូវវិធានការចាំបាច់នានា ដើម្បីដោះស្រាយនូវពាក្យបណ្តឹងនេះឲ្យបានយ៉ាងឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

គ. ការសុំប្តឹងដឹតចិត្តមិនត្រូវបានអនុញ្ញាតទេ

១០- ចំណុចចាប់ផ្តើមសម្រាប់ការកំណត់ណាមួយ ថាតើមានមូលដ្ឋានដើម្បីប្តឹងដឹតចិត្តចៅក្រមណាមួយចេញពីក្នុងសំណុំរឿងដែរឬអត់នោះ គឺជាការសន្និដ្ឋានដោយមិនលម្អៀងរបស់តុលាការ[17]។ ការធ្វើសេចក្តីសន្និដ្ឋាននេះ គឺភ្ជាប់គ្នាជាមួយនឹងចៅក្រមទាំងឡាយនៃ អវតក ដោយសារអំណាចនៃការស្បថចូលកាន់តំណែងរបស់ពួកគាត់ និងលក្ខណៈសម្បត្តិនៃការតែងតាំងពួកគាត់[18]។ ភាគីអ្នកប្តឹងសុំមានបន្ទុកក្នុងការដាក់ការសន្និដ្ឋានមិនត្រឹមត្រូវ ដែលដាក់លក្ខខណ្ឌខ្ពស់[19]។ ដើម្បីចង្អុលបង្ហាញភស្តុតាងអំពីការចោទប្រកាន់ណាមួយថាមានភាពលម្អៀង ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសម្រេចរបស់ចៅក្រមណាម្នាក់ ត្រូវតែបង្ហាញថាការសម្រេចនោះ គឺបណ្តាលឲ្យមានបុរេវិនិច្ឆ័យ ឬអាចមានការយល់ឃើញសមស្របថាជា និង<u>មិនមែនជាប់ទាក់ទងដោយពិតប្រាកដទៅនឹងការយកច្បាប់មកអនុវត្ត ឬទៅនឹងការវាយតម្លៃលើអង្គហេតុដែលពាក់ពន្ធនោះឡើយ</u>[20]។ អង្គជំនុំជម្រះបានយកមកអនុវត្តនូវការធ្វើតេស្តដែលធ្លាប់បានប្រើប្រាស់ដោយតុលាការអន្តរជាតិ

---

[16] ឯកសារលេខ **E314/2** អនុស្សរណៈពីលោកប្រធានអង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនលោកប្រធានគណៈកម្មាធិការរដ្ឋបាលតុលាការ (the Judicial Administration Committee), "ការជូនដំណឹងស្តីពីសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ប្តឹងដឹតចិត្តចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ជាទម្រង់ជំនួសនៃដំណោះស្រាយ", ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤។

[17] ឯកសារលេខ **E55/4** សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា, និង អៀង សារី ដែលប្តឹងដិតចិត្តចៅក្រម និល ណុន ចៅក្រម Silvia Cartwright, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc Lavergne និងចៅក្រម ធូ មណី, ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១, កថាខណ្ឌទី១២ (" សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា, និង អៀង សារី")។

[18] *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី១២។

[19] *ដូចគ្នានឹងខាងលើ* ។

[20] *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី១៣។

ផ្សេងៗទៀត[21] ក្នុងតុលាការនោះ លក្ខខណ្ឌតម្រូវអំពីភាពមិនលម្អៀងត្រូវបានរំលោភ មិនគ្រាន់តែចៅក្រមណាម្នាក់កំពុងតែលម្អៀងដោយជាក់ស្តែងប៉ុណ្ណោះទេ (“*ភាពលម្អៀងដោយអត្តនោម័ត*”) ក៏ប៉ុន្តែថែមទាំងស្តែងឲ្យឃើញពីភាពលម្អៀង (“*ភាពលម្អៀងដោយសត្យានុម័ត*”)[22]។

១១- ការស្តែងឲ្យឃើញពីភាពលម្អៀង បង្ហាញ*តាមរយៈ* ប្រសិនកាលៈទេសៈអាចធ្វើឲ្យអ្នកសង្កេតការណ៍ឯករាជ្យដែលបានទទួលដំណឹងត្រឹមត្រូវ ឈានដល់ក្តាប់បានដោយសមហេតុសមផលអំពីភាពលម្អៀង។ “អ្នកសង្កេតការណ៍ឯករាជ្យ”គឺជាមនុស្សដែលគិតពីសម្មតិកម្មបានត្រឹមត្រូវ ប្រកបដោយចំណេះដឹងគ្រប់គ្រាន់អំពីកាលៈទេសៈពាក់ព័ន្ធទាំងអស់ ដើម្បីធ្វើការវិនិច្ឆ័យដោយភាពសមហេតុសមផលអំពីថាតើលោកចៅក្រមដែលកំពុងតែរងការតវ៉ា មិនអាចនាំមកនូវភាពមិនលម្អៀង និងមិនប៉ះពាល់ដល់បញ្ហាដែលកំពុងកើតឡើងក្នុងករណីនេះដែរ ឬអត់[23]។ ជាផ្នែកមួយនៃការយល់ដឹងនេះ អ្នកសង្កេតការណ៍ឯករាជ្យត្រូវបានគេចាត់ទុកថា ត្រូវតែដឹងអំពីទំនៀមទំលាប់នៃភាពសុចរិត និងភាពមិនលម្អៀងរបស់តុលាការ និងដឹងអំពីការពិតដែលថា ភាពមិនលម្អៀង គឺជាភារកិច្ចមួយក្នុងចំណោមភារកិច្ចផ្សេងៗ ដែលចៅក្រមទាំងអស់ធ្វើសច្ចប្រណិធានដើម្បីគោរពតាម[24]។

១២- ច្បាប់យុត្តិសាស្ត្រអន្តរជាតិក៏បានទទួលស្គាល់ដោយស្របគ្នាផងដែរថា អ្នកសង្កេតការណ៍ឯករាជ្យបានយល់ថា ចៅក្រមទាំងឡាយសម្រេចដោយផ្អែកតែលើភស្តុតាងដែលបានបង្ហាញជូនតែប៉ុណ្ណោះនៅក្នុងពេលសវនាការ[25]។ ឧទាហរណ៍ដូចជា អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានកត់សម្គាល់ថា៖ “[អ្នកសង្កេតការណ៍ឯករាជ្យ] អាចដឹងថា ចៅក្រមទាំងឡាយនៃតុលាការនេះគឺជាចៅក្រមអាជីព” ដែលត្រូវបានអញ្ជើញឲ្យមកជំនុំជម្រះលើសំណុំរឿងមួយចំនួនដែលកើតចេញពីព្រឹត្តិការណ៍ដូចគ្នា ហើយពឹងផ្អែកលើព្រឹត្តិការណ៍ទាំងនោះ ដើម្បីកំណត់ជាភស្តុតាងនៅក្នុងរឿង

---

[21] សូមមេត្តាអាន , ឧទាហរណ៍ *រឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Anto Furundžija,* សំណុំរឿងលេខ IT -95-17/I-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី២១ កក្កដា ២០០០ (“សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍លើរឿងក្តីរបស់ *Furundžija*”) ត្រង់កថាខណ្ឌទី១៨៩។

[22] ឯកសារលេខ **E55/4** សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា, និង អៀង សារី, កំណត់សម្គាល់លេខ ១៧ *ខាងដើម*, ត្រង់កថាខណ្ឌទី១១។

[23] សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍លើរឿងក្តីរបស់ *Furundžija*, កំណត់សម្គាល់លេខ ២១ *ខាងដើម*, ត្រង់កថាខណ្ឌទី១៨៩។

[24] *រឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Radoslav Brđanin and Momir Talić,* សំណុំរឿងលេខ IT-99-36-PT, សេចក្តីសម្រេចលើពាក្យបណ្តឹងរបស់ Momir Talić សុំប្តឹងដឹតចិត្ត និងដកចៅក្រមមួយរូប, ចុះថ្ងៃទី១៨ ឧសភា ២០០០ (“សេចក្តីសម្រេចលើករណីរបស់*Talić*”) ត្រង់កថាខណ្ឌទី១៥។

[25] សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍លើរឿងក្តីរបស់ *Furundžija*, កំណត់សម្គាល់លេខ ២១ *ខាងដើម*, ត្រង់កថាខណ្ឌទី១៩០។

ក្តីពិសេសៗចំពោះមុខ"[26]។ ស្រដៀងគ្នានេះ តុលាការ ICC បានសម្រេចនៅក្នុងករណីរឿងក្តីរបស់ *Banda និង Jerbo ថា៖*

> *នៅពេលធ្វើការវាយតម្លៃទៅលើការស្តែងឱ្យឃើញពីភាពលម្អៀងតាមរយៈចក្ខុរបស់អ្នកសង្កេតការណ៍ឯករាជ្យថា ប្រសិនបើមិនមានការជំទាស់ គេសន្និដ្ឋានថា ចៅក្រមតុលាការ ជាចៅក្រមអាជីព ដែលហេតុនេះ អាស្រ័យទៅតាមបទពិសោធន៍ និងការហ្វឹកហាត់របស់ពួកគាត់ គឺមានសមត្ថភាពធ្វើការសម្រេចលើបញ្ហាដែលស្ថិតនៅចំពោះមុខខ្លួន នៅពេលផ្អែកតែទៅលើភស្តុតាងប៉ុណ្ណោះដែលបាននាំយកមក នៅក្នុងរឿងក្តីពិសេសមួយ*[27] ។

១៣- តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា ចៅក្រមទាំងឡាយត្រូវបានអនុញ្ញាតឱ្យធ្វើជាអធិបតីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌចំនួនពីរ ដែលចេញមកពីសំណុំអង្គហេតុតែមួយជាមួយគ្នា លុះត្រាតែសាលក្រមពីដំបូងមានការរកឃើញថា "ពិតជាធ្វើបុរេវិនិច្ឆ័យលើបញ្ហាពិរុទ្ធភាពរបស់ជនជាប់ចោទ"[28]។ ដើម្បីបង្ហាញមូលដ្ឋានក្នុងការប្តឹងជំទាស់ចៅក្រម ... ដើម្បីបង្ហាញមូលដ្ឋានក្នុងការប្តឹងដឹតចិត្ត បុរេវិនិច្ឆ័យបែបនេះអាចចាំបាច់ពាក់ព័ន្ធនឹងការសម្រេច "អំពីលក្ខខណ្ឌពាក់ព័ន្ធទាំងអស់ចាំបាច់ដើម្បីបង្កើតបានជាបទល្មើសព្រហ្មទណ្ឌ និងតើអ្នកដាក់ពាក្យប្តឹងមានពិរុទ្ធភាពក្នុងការប្រព្រឹត្តបទល្មើសនោះ ហួសពីវិមតិសង្ស័យដែរ ឬអត់"[29] ក្នុងករណី តុលាការមួយយល់ថា ខ្លួនមិនប្រកាសពិរុទ្ធភាពរបស់ជនជាប់ចោទនោះទេ ការស្តែងឱ្យឃើញនូវភាពលម្អៀងមួយ មិនបានកើតឡើងឡើយ[30] ។

---

[26] សេចក្តីសម្រេចលើរឿងក្តីរបស់*Talić*, កំណត់សម្គាល់លេខ ២៤ *ខាងដើម*, ត្រង់កថាខណ្ឌទី១៧។ [សង្កត់ន័យបន្ថែមដោយគូសបន្ទាត់ពីក្រោម]។

[27] *រឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Abdallah Banda Abakaer Nourain និង Saleh Mohammed Jerbo Jamus*, សំណុំរឿងលេខ ICC-02/05-03/09-344-Anx, សេចក្តីសម្រេចរបស់អង្គប្រជុំចៅក្រមពេញអង្គលើ "សំណើរបស់ក្រុមមេធាវីការពារក្តីដែលសុំប្តឹងដឹតចិត្តចៅក្រមមួយរូប ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០១២" (អង្គប្រជុំចៅក្រមពេញអង្គនៃតុលាការ ICC), ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១២, ត្រង់កថាខណ្ឌទី១៤ [សង្កត់ន័យបន្ថែមដោយអក្សរទ្រេត]។

[28] *រឿងក្តីរបស់ Poppe ទល់នឹង ប្រទេសហូឡង់*, សាលក្រម, តុលាការសិទ្ធិមនុស្សអឺរ៉ុប *(សំណុំរឿងលេខ 32271/04)*, ចុះថ្ងៃទី២៤ មីនា ២០០៩, កថាខណ្ឌទី២៦ [សង្កត់ន័យបន្ថែមដោយគូសបន្ទាត់ពីក្រោម] (" សេចក្តីសម្រេចលើរឿងក្តីរបស់*Poppe*")។

[29] *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី២៨ [សង្កត់ន័យបន្ថែមដោយគូសបន្ទាត់ពីក្រោម]។

[30] *រឿងក្តីរបស់ Schwarzenberger ទល់នឹង ប្រទេសអាល្លឺម៉ង់*, សាលក្រម, តុលាការសិទ្ធិមនុស្សអឺរ៉ុប *(សំណុំរឿងលេខ 75737/01)*, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៦ ត្រង់កថាខណ្ឌទី៤៣។

១៤- មិនមានសេចក្តីសន្និដ្ឋានណាមួយក្នុងសំណើនេះ បានបង្ហាញពីមូលដ្ឋាន សម្រាប់ធ្វើការជំនុំជម្រះដោយផ្អែកលើមូលដ្ឋាននៃការរកឃើញកាលពីលើកមុនៗ អំពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ ខៀវ សំផន នោះឡើយ។ នៅក្នុងសំណុំរឿងលេខ០០២/០១ គ្មានការរកឃើញណាមួយដែលថា ខៀវ សំផន ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការចោទប្រកាន់ណាមួយក្នុងចំណោមការចោទប្រកាន់នានាដែលនៅសេសសល់សម្រាប់សំណុំរឿងលេខ០០២/០២នោះឡើយ។ ឧទាហរណ៍ មិនមានការរកឃើញណាមួយដែលបង្ហាញឲ្យហួសពីវិមតិសង្ស័យថា ខៀវ សំផន ទទួលខុសត្រូវចំពោះមនុស្សរាប់ពាន់នាក់ដែលត្រូវបានគេធ្វើទារុណកម្ម និងសម្លាប់នៅមន្ទីរស-២១ ឬនៅមន្ទីរសន្តិសុខដទៃទៀតឡើយ។ មិនមានការរកឃើញថាគាត់មានពិរុទ្ធភាពនៅក្នុងឧក្រិដ្ឋកម្ម ពីបទរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬការរំលោភសេពសន្ថវៈដែលបានប្រព្រឹត្តនៅក្នុងរង្វង់នៃការរៀបអាពាហ៍ពិពាហ៍ទាំងនោះ ឬថា រូបគាត់ផ្ទាល់ ទទួលខុសត្រូវខាងព្រហ្មទណ្ឌពីបទប្រល័យពូជសាសន៍ ឬពីបទចោទប្រកាន់ណាមួយដែលនៅសេសសល់ ដែលជាកម្មវត្ថុនៃសំណុំរឿងលេខ០០២/០២នោះឡើយ។

១៥- អង្គជំនុំជម្រះមិនបានរកឃើញអំពីធាតុផ្សំនៃបទល្មើស ដែលទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មណាមួយក្នុងសំណុំរឿងលេខ០០២/០២ ឬតួនាទីជាក់លាក់របស់សហជនជាប់ចោទ និងអំពីការអនុវត្តគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យនៅក្នុងអំឡុងពេលពាក់ព័ន្ធនោះឡើយ។ អង្គជំនុំជម្រះមិនបានធ្វើការសម្រេចអំពីថាតើ និងរបៀបដែលជនជាប់ចោទ ត្រូវទៅតាម "លក្ខខណ្ឌពាក់ព័ន្ធ "ទាំងអស់"[31] ចាំបាច់ ដើម្បីបង្កើតបានជាបទល្មើសព្រហ្មទណ្ឌ" ដែរ ឬអត់ និងដោយរបៀបណា[32] ទាក់ទងនឹងឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់នៅក្នុងសំណុំរឿងលេខ០០២/០២ ហើយជាការប្រាកដណាស់ថាមិនអាចទាមទាររកឲ្យឃើញថា ខៀវ សំផន "មានពិរុទ្ធភាពហួសពីវិមតិសង្ស័យ" [33] ចំពោះបទល្មើសបែបនេះបានឡើយ។

១៦- ជាងនេះទៅទៀត ដោយមេធាវីការពារក្តី ខៀវ សំផន បានទទួលស្គាល់ ខ្លឹមសារទាំងអស់ដែលបានជំទាស់នៅក្នុងសំណុំរឿង០០២/០១ ថាសាលក្រមមាននៅក្នុងផ្នែកមួយនៃសាលក្រម ដែលមានចំណងជើងថា "ទិដ្ឋភាពប្រវត្តិសាស្ត្រ"។ អង្គជំនុំជម្រះបានពន្យល់ថា៖ "ភស្តុតាងនានាដែលបានពិភាក្សានៅក្នុងផ្នែកនេះ គឺមានគោលបំណងបង្ហាញភស្តុតាងឲ្យឃើញអំពីបរិបទខាងប្រវត្តិសាស្ត្រ

---

[31] សេចក្តីសម្រេចលើរឿងក្តីរបស់*Poppe*, កំណត់សម្គាល់លេខ ២៨ *ខាងដើម*, ត្រង់កថាខណ្ឌទី២៨។

[32] *ដូចគ្នានឹងខាងលើ*។

[33] *ដូចគ្នានឹងខាងលើ*។

និងអង្គហេតុនៃព្រឹត្តការណ៍នានាដែលស្ថិតនៅក្នុងវង្វង់យុត្តាធិការពេលវេលានៃ អវតក"[34]។ អង្គជំនុំជម្រះថែមទាំងបានពន្យល់ដែរថា "អត្ថិភាពនៃគោលនយោបាយនីមួយៗ ក្នុងចំណោមគោលនយោបាយទាំងនេះ ត្រូវបានដេញដោលនៅក្នុងផ្នែកនេះ ដើម្បីផ្តល់រូបភាពទាំងមូលនៃស្ថានការណ៍ នៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥"[35]។ មេធាវីការពារក្តី ខៀវ សំផន បានទាមទារថា មានគោលនយោបាយតែពីរប៉ុណ្ណោះរបស់កម្ពុជាប្រជាធិបតេយ្យ អាចចាត់ទុកថាត្រឹមត្រូវ ស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿងលេខ០០២/០១។ ប៉ុន្តែនេះមើលរំលងចំពោះសេចក្តីពន្យល់ច្បាស់លាស់របស់អង្គជំនុំជម្រះថា៖

> *ចាប់ពីដើមដំបូងនៃសំណុំរឿងលេខ០០២/០១មក អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីនានាថា អង្គជំនុំជម្រះអាចដឹកនាំលើភស្តុតាងពាក់ព័ន្ធនឹងគោលនយោបាយទាំងប្រាំ ដើម្បីធ្វើជាប្រវត្តិដើម ប៉ុន្តែ អង្គជំនុំជម្រះអាចដេញដោលលើការអនុវត្តតែលើគោលនយោបាយទាំងនោះដែលពាក់ព័ន្ធទៅនឹងសំណុំរឿងលេខ០០២/០១តែប៉ុណ្ណោះ (គឺថា ការជម្លៀសចេញដោយបង្ខំ និងការសម្លាប់ពួកអ្នកដែលគេបានអះអាងថាជាខ្មាំងរបស់របបនោះ)*[36]។

ពុំមានខ្លឹមសារណាមួយដែលមេធាវីការពារក្តីរបស់ ខៀវ សំផន បានលើក ធ្វើការកំណត់អំពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់បុគ្គល*ណាមួយ* ចំពោះការចោទប្រកាន់*ណាមួយ* ទាំងក្នុងសំណុំរឿងលេខ០០២/០១ ឬទាំងក្នុងសំណុំរឿងលេខ០០២/០២នោះឡើយ។ ដូចដែលអង្គជំនុំជម្រះបានបញ្ជាក់ ហើយមេធាវីការពារក្តី ខៀវ សំផន បានទទួលស្គាល់ គេគ្រាន់តែផ្តល់នូវខ្លឹមសារ និងទិដ្ឋភាពប្រវត្តិសាស្ត្រតែប៉ុណ្ណោះ។

---

34 ឯកសារលេខ **E313** សាលក្រមនៃសំណុំរឿងលេខ០០២/០១ , ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ត្រង់សេចក្តីពន្យល់នៅលេខយោងជើងទំព័រលេខ១៩៥។

35 *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី៧៩។

36 *ដូចគ្នានឹងខាងលើ* ត្រង់សេចក្តីពន្យល់នៅលេខយោងជើងទំព័រលេខ២៨៧។ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីនានាអំពីការដាក់បញ្ចូលនូវគោលនយោបាយចំនួនប្រាំ សម្រាប់ប្រវត្តិដើម និងជាបរិបទ យ៉ាងឆាប់នៅត្រឹមថ្ងៃទី៨ ខែតុលា ឆ្នាំ២០១១៖ សូមមេត្តាអានឯកសារលេខ **E124/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខ E124/2) និងសំណើពាក់ព័ន្ធនានាព្រមទាំងឧបសម្ព័ន្ធ, ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១១ ត្រង់កថាខណ្ឌទី១១ ["[]សេចក្តីសម្រេចនេះបន្តទៀតថា ក្នុងអម្លុងការបែងចែកការជំនុំជម្រះក្តីនៅដំណាក់កាលដំបូង អង្គជំនុំជម្រះនឹងធ្វើការពិចារណាទៅលើតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទ ដែលទាក់ទងទៅនឹងគោលនយោបាយទាំងអស់ដែលពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល"]។

១៧- ការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២ បានបង្កើតស្ថានភាពមួយគត់ដែលមាននៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ ពីមុនមក ពុំធ្លាប់មានទាល់តែសោះ ជនជាប់ចោទនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ឬតុលាការមានលក្ខណៈជាអន្តរជាតិ ត្រូវស្ថិតនៅក្រោមការជំនុំជម្រះលើកទីពីរ ដោយផ្អែកលើការចោទប្រកាន់លើអង្គហេតុដាច់ដោយឡែក ដែលជាផ្នែកនៃឯកសារចោទប្រកាន់តែមួយដូចគ្នា។ ជាលទ្ធផល ច្បាប់យុត្តិសាស្ត្រអន្តរជាតិបានផ្តល់នូវសេចក្តីណែនាំដែលមានកម្រិតអំពីថាតើជនជាប់ចោទអាចត្រូវបានជំនុំជម្រះដោយចៅក្រមដដែល ឬមួយយ៉ាងណា នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការទាំងពីរ។

១៨- យ៉ាងណាក៏ដោយ នៅតាមកម្រិតជាតិ គឺជាការអនុវត្តតាមធម្មតាចំពោះចៅក្រមដដែល ត្រូវធ្វើការជំនុំជម្រះលើករណីរឿងក្តីជាច្រើនប្រឆាំងនឹងចុងចោទតែម្នាក់។ ដោយឡែក សហរដ្ឋអាមេរិក បានផ្តល់នូវយុត្តិសាស្ត្រទូលំទូលាយស្តីពីចំណុចជាក់លាក់នេះ។ ដូចដែលតុលាការកំពូល បានសម្រេចនៅក្នុងរឿងក្តី *Liteky និងគូកន ទល់នឹង សហរដ្ឋអាមេរិក,* “ត្រូវបានគេចាត់ទុកជាយូរមកហើយថាជា ធម្មតា និងសមស្រប សម្រាប់ចៅក្រមម្នាក់ជំនុំជម្រះ [...] ក្នុងសវនាការជាប់ៗគ្នា ដែលជាប់ទាក់ទងនឹងចុងចោទដដែល”[37]។ ដូច្នេះ ការរកឃើញពីមុនៗរបស់ចៅក្រមម្នាក់នៅក្នុងសំណុំរឿងដាច់ដោយឡែកពីគ្នា, បើទោះជាមានការពាក់ព័ន្ធគ្នាក៏ដោយ, ដែលប្រឆាំងនឹងជនជាប់ចោទដដែល គឺមិនស្តែងឲ្យឃើញពីភាពលម្អៀង សម្រាប់ដិតចិត្តចៅក្រមឡើយ[38]។

១៩- ស្រដៀងគ្នានេះដែរ គេបានសម្រេចថា មិនមែនជាមូលដ្ឋានមួយសម្រាប់ប្តឹងដិតចិត្តដែលចៅក្រមម្នាក់ជំនុំជម្រះសំណុំរឿងមួយដោយបង្វិលទៅវិញ។ តុលាការសាលាឧទ្ធរណ៍របស់សហរដ្ឋអាមេរិក សម្រាប់រដ្ឋទីប្រាំបួន បានសម្រេចថា៖ “អង្គហេតុដែលថា ចៅក្រមជំនុំជម្រះដែលស្ថិតនៅក្នុងការជំនុំជម្រះលើកដំបូង ក៏ជាចៅក្រមជំនុំជម្រះក្តីដែលស្ថិតនៅក្នុងការជំនុំជម្រះលើកទីពីរដែរ គឺមិនមានលក្ខណៈគ្រប់គ្រាន់ ដើម្បីបង្កើតឲ្យមានភាពលម្អៀង និងប៉ះពាល់ឡើយ”[39]។

២០- មិនជំទាស់ទេថា សាលក្រមនៅក្នុងសំណុំរឿង០០២/០១ មានការរកឃើញនៅលើបញ្ហាទាំងឡាយដែលនឹងលេចឡើងជាថ្មីយ៉ាងប្រាកដនៅក្នុងសំណុំរឿង០០២/០២។ ជាឧទាហរណ៍ ការរកឃើញ

---

[37] *Liteky និងគូកន ទល់នឹង សហរដ្ឋអាមេរិក,* 510 U.S. 540 ត្រង់ 551។

[38] សូមអានផងដែរ *រដ្ឋ Connecticut ទល់នឹង Daniel Webb,* 238 Conn. 389, ត្រង់ 461 (ឆ្នាំ១៩៩៦)។

[39] *ប្រទេសប៉ូឡូញ ទល់នឹង Stewart*, [ឆ្នាំ១៩៩៧] 117 F.3d 1094, 97 Cal. Daily Op. Serv. 4854, 97, D.A.R. 7958. ត្រង់កថាខណ្ឌ ៦៥។

នានាទាក់ទងនឹងធាតុផ្សំបរិបទនៃបទល្មើសព្រហ្មទណ្ឌប្រឆាំងមនុស្សជាតិ ដូចជា អង្គហេតុដែលថានៅក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ មានជាផ្នែកនៃការវាយប្រហារទូលំទូលាយ និងជាប្រព័ន្ធ ទៅលើប្រជាជនស៊ីវិល នឹងមានការទាក់ទងគ្នាយ៉ាងពិតប្រាកដម្តងទៀត ទៅនឹងបទចោទទាំងឡាយដែលរង់ចាំការសម្រេច។ ស្រដៀងគ្នានេះដែរ ភស្តុតាងទាក់ទងនឹងមុខងារនានាដែលបានកាន់កាប់ដោយ ខៀវ សំផន, សិទ្ធិអំណាចរបស់គាត់, របៀបនៃសេចក្តីសម្រេចដែលបានធ្វើឡើងនៅក្នុងកម្ពុជាប្រជាធិបតេយ្យ, របៀបនៃការដាក់ទិសដៅដែលបានប្រាស្រ័យទាក់ទងគ្នាចេញពីមជ្ឈឹមបក្ស និងរបាយការណ៍ដែលបានទទួលដោយមជ្ឈឹមបក្ស ព្រមទាំងការចូលរួមចំណែករបស់ ខៀវ សំផន នៅក្នុងផែនការរួម ទាំងអស់នេះប្រាកដជាលេចឡើងម្តងទៀតនៅក្នុងសំណុំរឿង០០២/០២ ជាមិនខាន។

២១- ជាការច្បាស់ណាស់ ដែលថាមេធាវីការពារក្តី ខៀវ សំផន មិនបានយល់ព្រមទៅនឹងការរកឃើញជាច្រើនរបស់អង្គជំនុំជម្រះនេះ នៅក្នុងសាលក្រមនៃសំណុំរឿង០០២/០១ ចំពោះសហព្រះរាជអាជ្ញាមិនពេញចិត្តទៅនឹងការរកឃើញមួយចំនួន។ ក៏ប៉ុន្តែ អង្គជំនុំជម្រះនេះបានរកឃើញ នៅក្រោយការអនុវត្តច្បាប់ទៅលើភស្តុតាង ដែលបានដាក់បង្ហាញនៅក្នុងអំឡុងពេលសវនាការមួយដែលនៅពេលនោះ ខៀវ សំផន មានវត្តមាន និងត្រូវបានការពារដោយមេធាវីការពារក្តីដែលប្រកបទៅដោយបទពិសោធន៍ ដែលបានជំទាស់ខ្លាំងខ្លាទៅនឹងការចោទប្រកាន់នេះ។ អង្គហេតុដែលថាអង្គជំនុំជម្រះនេះ បន្ទាប់ពីបានស្តាប់ភស្តុតាង និងបានពិចារណាលើអំណះអំណាងទាំងអស់ បានសម្រេចថា ភាគីមួយមិនចូលចិត្ត មិនបង្ហាញពីភាពលម្អៀងទេ ឬសូម្បីតែការស្តែងឲ្យមានភាពលម្អៀងនោះក៏គ្មានដែរ។ ចៅក្រមបានសម្រេចលើភស្តុតាងចំពោះមុខ។ នេះគឺជាមុខងាររបស់ចៅក្រម។ ការជំនុំជម្រះមួយមិនមែនជាព្រឹត្តិការណ៍កីឡាទេ ដែលនៅក្នុងនោះ គោលដៅ គឺការផ្តល់ភាគីម្ខាងៗនូវឱកាសស្មើៗគ្នាដើម្បីឈ្នះ។ ផ្ទុយទៅវិញ គោលដៅនៃការជំនុំជម្រះ គឺដើម្បីឈានដល់សាលក្រមមួយដែលប្រកបដោយយុត្តិធម៌ ដែលមានការអនុវត្តច្បាប់បានត្រឹមត្រូវ និងដោយស្របទៅលើភស្តុតាងដែលបានដាក់បង្ហាញ។

២២- ដូច្នេះ អង្គហេតុដែលថាចៅក្រមម្នាក់ បានរកឃើញជាមុននូវអង្គហេតុ និងអង្គច្បាប់ ប្រឆាំងនឹងភាគីណាមួយក្នុងកិច្ចដំណើរការនីតិវិធី មិនបានដិតចិត្តចៅក្រមនោះមិនឲ្យចូលរួមសវនាការ ឬមិនឲ្យចូលរួមក្នុងនីតិវិធីឧទ្ធរណ៍ដែលមានបញ្ហាដែលអាចកើតឡើងនោះទេ។ ជាឧទាហរណ៍ នៅក្នុងករណីរឿងក្តីរបស់ *Brđanin និង Talić* មេធាវីការពារក្តីរបស់ Talić បានប្តឹងដិតចិត្តចៅក្រម Mumba ឲ្យចេញពីអង្គជំនុំជម្រះសាលាដំបូងមួយនៃតុលាការ ICTY ដោយផ្អែកលើ

មូលដ្ឋានដែលថា លោកស្រីបានចូលរួមអង្គជំនុំជម្រះឧទ្ធរណ៍នៅក្នុងសំណុំរឿង *Tadić* ពីដំបូង ដែលបានសម្រេចថាសង្គ្រាមនៅ Bosnia និង Herzegovina ក្នុងឆ្នាំ១៩៩២ គឺជាជម្លោះប្រដាប់អាវុធអន្តរជាតិមួយ។ ញត្តិរបស់មេធាវីការពារក្តីត្រូវបានច្រានចោល ទោះបីមេធាវីការពារក្តីបានតវ៉ាទៅនឹងមូលដ្ឋានអង្គហេតុនៃជម្លោះប្រដាប់អាវុធអន្តរជាតិនោះក៏ដោយ។ អង្គជំនុំជម្រះសាលាដំបូង បានដកស្រង់សំណុំរឿងក្នុងស្រុកដើម្បីគាំទ្រនូវគោលការណ៍ ដែលថាចៅក្រមនឹងមិនមានភាពលម្អៀង ដោយសារគ្រាន់តែចៅក្រមបានសម្រេច ឬធ្លាប់បានប្រឈមនឹងបញ្ហានានាពាក់ព័ន្ធអង្គហេតុ និងអង្គច្បាប់ ក្នុងសំណុំរឿងដែលមានអង្គហេតុពាក់ព័ន្ធ។

> *"មានស្ថានភាពជាច្រើនដែលនៅក្នុងនោះ សេចក្តីសម្រេចពីមុនៗរបស់មន្ត្រីតុលាការលើបញ្ហានានាខាងអង្គហេតុ និងអង្គច្បាប់ អាចធ្វើឱ្យមានការរំពឹងទុកថាគាត់ទំនងជានឹងសម្រេចលើបញ្ហាទាំងឡាយនៅក្នុងសំណុំរឿងពិសេស ដោយផ្ទុយទៅនឹងសំណុំរឿងមួយរបស់ភាគី។ ប៉ុន្តែ ការណ៍នេះមិនមែនមានន័យថា គេនឹងដោះស្រាយលើបញ្ហានានានៅក្នុងសំណុំរឿងផ្សេងក្រៅពីមានភាពមិនលម្អៀង និងមិនបាត់បង់ប្រយោជន៍ ក្នុងន័យដែលថាវោហាសព្ទត្រូវបានប្រើប្រាស់នៅក្នុងសិទ្ធិអំណាច ឬសេចក្តីសម្រេចពីមុនៗរបស់គេនឹងផ្តល់ជាមូលដ្ឋានមួយដែលអាចទទួលយកបាន សម្រាប់ទាញសេចក្តីសន្និដ្ឋានថាមានការបារម្ភសមហេតុសមផលមួយ ដែលថាគេនឹងដោះស្រាយនូវបញ្ហានានាទៅតាមរបៀបនេះ។ នៅក្នុងសំណុំរឿងបែបនេះ ការប្តឹងជំទាស់ចៅក្រមគឺត្រូវបានធ្វើឡើងតែតាមរយៈការបង្ហាញថាមានការបារម្ភសមហេតុសមផលមួយ លើភាពលម្អៀងដោយហេតុផលនៃបុរេវិនិច្ឆ័យ ហើយការណ៍នេះត្រូវតែ "ធ្វើឡើងដោយហ្មត់ចត់"។ ទោះបីជាមានសារៈសំខាន់ដែលថា យុត្តិធម៌ត្រូវតែធ្វើឱ្យឃើញថាមានយ៉ាងណាក៏ដោយ ក៏មន្ត្រីតុលាការដែលបំពេញករណីយកិច្ចរបស់ខ្លួនត្រូវបំពេញកាតព្វកិច្ច ហើយតាមរយៈការយល់ព្រមទាប់រហ័ស ពេកទៅនឹងការបង្ហាញឱ្យឃើញថាមានការលម្អៀង មិនត្រូវលើកទឹកចិត្តដល់ភាគី តាមរយៈការប្តឹងជំទាស់ចៅក្រម ឱ្យជឿថាភាគីនឹងឱ្យចៅក្រមជំនុំជម្រះសំណុំរឿងខ្លួន ដែលបានគិតថាទំនងជានឹងធ្វើការសម្រេចសំណុំរឿងឱ្យខ្លួនបានជោគជ័យ"*[40]។

[40] សេចក្តីសម្រេចលើរឿងក្តីរបស់ *Talić*, កំណត់សម្គាល់*ខាងលើ* លេខ២៤ ត្រង់១៨, ដកស្រង់ចេញពី J. Mason នៃតុលាការកំពូលរបស់ប្រទេសអូស្ត្រាលី នៅក្នុង *Re JRL*។ *CJL ដោយភាគីតែម្ខាង* (ឆ្នាំ១៩៨៦) 161 CLR 342 ត្រង់ 352។ ខ្លឹមសារដែលត្រូវបានយល់ព្រម ឱ្យធ្វើការដកស្រង់ចេញពី *សេចក្តីសម្រេចលើញត្តិរបស់លោកសាស្ត្រាចារ្យ Vojislav Šešelj ស្នើសុំប្តឹងជំទាស់ចៅក្រម O-Gon Kwon និងចៅក្រម Kevin Parker*, ១៩ វិច្ឆិកា ២០១០, កថាខណ្ឌ ២៨។

២៣- គោលការណ៍ដែលបានអនុវត្តនៅទីនេះ។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា សំណុំរឿង០០២/០១ និង០០២/០២ គឺជាសំណុំរឿងខុសគ្នា ទោះបីជាមានការទាក់ទងគ្នាខាងអង្គហេតុ និងអង្គច្បាប់ក៏ដោយ។ អង្គជំនុំជម្រះនេះបានធ្វើការសម្រេចមួយចំនួននៅក្នុងសំណុំរឿង០០២/០១ ប្រឆាំងទៅនឹងជំហររបស់មេធាវីការពារក្តី ខៀវ សំផន។ យ៉ាងណាក៏ដោយ យុត្តិសាស្ត្រអន្តរជាតិ គឺមានលក្ខណៈច្បាស់លាស់។ លទ្ធភាពតិចតួចនៃសំណុំរឿងមិនអាចប្តឹងជំទាស់អំពីអគតិបានធ្វើឲ្យប្រសើរឡើងនូវការជំនុំជម្រះសំណុំរឿង០០២/០២ បានទេ។

III. ដំណោះស្រាយដែលស្នើសុំ

២៤- ដើម្បីធានាឲ្យមានដំណើរការឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះ៖

ក. **បញ្ជាក់** លើសេចក្តីសម្រេចពីមុនរបស់ខ្លួនលេខ **E301/5/5/1** ហើយ បដិសេធ សំណើរបស់មេធាវីការពារក្តី ខៀវ សំផន ដែលស្នើសុំពន្យារការចាប់ផ្តើមសំណុំរឿង០០២/០២ រហូតទាល់តែមានសាលដីកាស្ថាពរក្នុងសំណុំរឿង០០២/០១ ជាមុនសិន។

ខ. **ប្រកាសថា** ផ្នែកដែលនៅសេសសល់នៃញត្តិនេះ ជាសំណើមួយនៅក្រោមវិធាន៣៤ នៃវិធានផ្ទៃក្នុង សម្រាប់ប្តឹងជំទាស់អំពីអគតិនៃអង្គជំនុំជម្រះសាលាដំបូងទាំងមូល ហើយបញ្ជូនញត្តិ និងចម្លើយតបនេះជាបន្ទាន់ ទៅក្រុមពិសេសដែលបានបង្កើតឡើងដោយគណៈកម្មាធិការរដ្ឋបាលតុលាការ សម្រាប់គោលបំណងនេះ។ និង

គ. **បញ្ជាក់ថា** ដោយអនុលោមតាមវិធាន៣៤(៥) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះនឹងត្រូវដំណើរការនីតិវិធីលើរាល់បញ្ហាទាំងអស់ពាក់ព័ន្ធនឹងសវនាការមុនអង្គសេចក្តី និងអង្គសេចក្តី ក្នុងសំណុំរឿង០០២/០២ ដោយអាស្រ័យទៅលើការកំណត់ចុងក្រោយរបស់ក្រុមពិសេស លើសំណើសុំប្តឹងជំទាស់អំពីអគតិ៕

កាលបរិច្ឆេទ	ឈ្មោះ	ទីកន្លែង	ហត្ថលេខា
ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៤	**លោកស្រី ជា លាង** សហព្រះរាជអាជ្ញា	ភ្នំពេញ	
	លោក Nicholas KOUMJIAN សហព្រះរាជអាជ្ញា		